ង/ អង្គភាពមានសមត្ថកិច្ច ក្នុងការផ្តល់លេខយានយន្តគ្រប់ប្រភេទត្រូវពិនិត្យប្រភព និងលិខិតស្នាមអោយបានច្បាស់លាស់ ។

រដ្ឋាភិបាលជាតិបណ្តោះអាសន្ន កម្ពុជា និង ខិតខំធ្វើសហប្រតិបត្តិការអោយកាន់តែជិតស្និទ ថែមទៀត ជាមួយអាជ្ញាធរអ៊ុនតាក់ គ្រប់ថ្នាក់ដើម្បីគ្នាប់បានពត៌មាន ទាន់ពេលវេលា ងាយស្រួលក្នុងការ ធ្វើប្រតិបត្តិការស្រាវជ្រាវតាមដានត្រួតពិនិត្យ អំពើលួចប្លន់ទ្រព្យសម្បត្តិរបស់អាជ្ញាធរអ៊ុនតាក់ ។

ទទួលបានសារាចរនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ក្រសួង ហិរញ្ញវត្ថុ ( គយនិង រដ្ឋាករ ) ក្រសួងដឹកជញ្ជូន និង ខេត្ត ក្រុង ត្រូវចាត់តាំងអនុវត្តដោយរួមសហការជា មួយអាជ្ញាធរអ៊ុនតាក់ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *

ភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរ លេខ ០៥ សរ**

## សូមទូលថ្វាយ និង ជំរាបជូន

- ព្រះអង្គម្ចាស់ ឯកឧត្តមរដ្ឋមន្ត្រីគ្រប់ក្រសួង
- អស់លោក អភិបាលគ្រប់ខេត្តក្រុង

**កម្មវត្ថុ** : អំពីបញ្ហាមួយចំនួនជុំវិញការតែងតាំងមន្ត្រី និយោជិត សំរាប់ក្រសួង ស្ថាប័ននីមួយៗ ។

**យោង** : សេចក្តីប្រកាស នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ចុះថ្ងៃទី ០២ខែ កក្កដា ឆ្នាំ១៩៩៣ ។

បច្ចុប្បន្ននេះ នៅតាមក្រសួងស្ថាប័នមួយចំនួន ក្នុងនោះមានក្រសួងដែលមានពីមុនមកស្រាប់ និងក្រសួងដែលទើបនឹងបង្កើតថ្មីផង មានលេចចេញនូវបាតុភាពជ្រើសរើសគ្រប់ខណ្ឌ និង បុគ្គលិកថ្មីបំរុង និង តែងតាំង បន្ថែមនៅក្នុងក្រសួង និង ស្ថាប័នទាំងនេះទៀត នៅពេលដែលក្រសួង និង ស្ថាប័ននីមួយ ៗ កំពុងត្រូវរែកអំរែកយ៉ាង ធ្ងន់ធ្ងរ ដោយសារមានចំនួនមន្ត្រី បុគ្គលិក និយោជិត ច្រើនលើសចំនួនដែល ចាំបាច់រួចទៅហើយ និង

នៅពេលដែល រដ្ឋាភិបាលកំពុងមានការលំបាកខាងហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ។

ម្យ៉ាងទៀតការដាក់អោយក្បាលម៉ាស៊ីនរដ្ឋបាល មានសភាពជាកម្លាំងអព្យាក្រឹត្យជាកត្តាមួយសំខាន់ណាស់សំរាប់ស្ថេរភាពនយោបាយ ក្នុងសភាពការណ៍រួមរបស់ប្រទេសជាតិនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី ។

ចំពោះមុខសភាពការណ៍នេះ រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ណែនាំគ្រប់ក្រសួងស្ថាប័ន ខេត្ត - ក្រុង ទូទាំងប្រទេសដូចតទៅ ។

១- ត្រូវប្រើ ចាត់តាំង និង តែងតាំងក្របខ័ណ្ឌ និង បុគ្គលិកដែលមានស្រាប់អោយអស់លទ្ធភាពដែល អាចធ្វើទៅបាន ។ ការជ្រើសរើស ឬតែងតាំងបន្ថែមថ្មីទៀត ត្រូវអនុលោមទៅតាមសេចក្តីត្រូវការចាំបាច់នៅក្នុងក្រសួង ហើយត្រូវមានការយល់ព្រមអនុញ្ញាតពីរដ្ឋាភិបាលជាមុនសិន ។

២- ចំពោះមន្ត្រីរដ្ឋការសំរាប់ក្រសួងដែលទើបបង្កើតថ្មី ទីប្រឹក្សារដ្ឋមន្ត្រី ជំនួយការជុំវិញ រដ្ឋមន្ត្រី កម្មាភិបាលជំនាញ ដែលមានសមត្ថភាពខ្ពស់ និង ចាំបាច់គឺក្រសួង ឬ ស្ថាប័នទាំងនេះអាចលើក សំណើជូនគណៈរដ្ឋមន្ត្រី ។ គណៈរដ្ឋមន្ត្រី នឹង ពិនិត្យសំណើដោយផ្អែកទៅលើតំរូវការចាំបាច់ និង យោបល់របស់ក្រសួងមុខងារសាធារណៈដែល នឹង បញ្ជាក់ពីនីតិក្រមសមស្របក្នុងការជ្រើសរើសមន្ត្រី រដ្ឋការ នឹង ផ្អែកលើលទ្ធភាពហិរញ្ញវត្ថុដែលបញ្ជាក់ដោយ ក្រសួងហិរញ្ញវត្ថុ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ននិងខេត្ត ក្រុង ត្រូវចាត់តាំងអនុវត្ត អោយមានប្រសិទ្ធភាពខ្ពស់ ។

ជ - សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី**

ហត្ថលេខា

តាក ឈន                អ៊ុច ផន

* * * *